# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ៤៤៨ អយក.បក

ថ្ងៃ ចន្ទ ៦ កើត ខែ មាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០២៦

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវ អគ្គលេខាធិការ អគ្គនាយក អគ្គាធិការ**
**ឯកឧត្តម លោកជំទាវ សាកលវិទ្យាធិការ នាយកវិទ្យាស្ថាន**
**ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រធានអង្គភាពក្រោមឱវាទទីស្តីការក្រសួង**
**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ករណីត្រៀមកញ្ចប់ឥណទានថវិកាឆ្នាំ២០២៦ សម្រាប់ចុះជួយគាំទ្រសាលារៀនសាធារណៈគោលដៅ ដែលរងគ្រោះដោយសង្គ្រាមឈ្លានពានតាមតំបន់ព្រំដែនប្រទេសកម្ពុជានិងថៃ។

**យោង៖** ចំណារឯកភាពរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា លើកំណត់បង្ហាញរឿងនាយកដ្ឋានហិរញ្ញវត្ថុ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០២៦។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន ឯកឧត្តម លោកជំទាវ លោក លោកស្រី ជ្រាបថា៖ ដោយមានការផ្ទុះសង្គ្រាមយ៉ាងធ្ងន់ធ្ងរចំនួនពីរលើកនៅតាមព្រំដែនរវាងប្រទេសកម្ពុជាជាមួយប្រទេសថៃដែលជាហេតុធ្វើឱ្យប៉ះពាល់ដល់ការសិក្សារបស់សិស្សានុសិស្សយ៉ាងខ្លាំងក្នុងខេត្តជាប់ព្រំដែនចំនួន៧ មានជាអាទិ៍ ខេត្តឧត្តរមានជ័យ ព្រះវិហារ បន្ទាយមានជ័យ បាត់ដំបង សៀមរាប កោះកុង និងពោធិ៍សាត់។ ទន្ទឹមនឹងនេះ បន្ទាប់ពីមានកិច្ចព្រមព្រៀងបទឈប់បាញ់កាលពីថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥ រវាងប្រទេសទាំងពីរក៏នៅមានគ្រឹះស្ថានសិក្សាសាធារណៈមួយចំនួនមិនទាន់វិលទៅប្រក្រតីភាពវិញទេ ជាក់ស្តែងគិតត្រឹមថ្ងៃទី១៤ ខែមករា ឆ្នាំ២០២៦ ជាពិសេសខេត្តចំនួន៣ ដែលរងគ្រោះខ្លាំងជាងគេគឺខេត្តឧត្តរមានជ័យ បន្ទាយមានជ័យ និងព្រះវិហារ ជាហេតុធ្វើឱ្យសាលារៀនសាធារណៈចំនួន៦៧កន្លែង បន្តបិទទ្វារ ប៉ះពាល់ដល់ការបំពេញការងាររបស់គ្រូបង្រៀនចំនួន៤៧៥នាក់ និងសិស្សានុសិស្សចំនួន១២ ២៤៦នាក់ ដោយគ្រឹះស្ថានទាំងនោះរងការខូចខាតយ៉ាងដំណំលើហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀនសាធារណៈ ជាអាទិ៍ អគារសិក្សា បន្ទប់រៀនដំបូល បន្ទប់ទឹក បរិស្ថាន បណ្ណាល័យ រោងបាយសិស្ស ផ្ទះបាយ កន្លែងស្តុកទឹក សម្ភារបរិក្ខារបច្ចេកទេស សម្ភារប្រើប្រាស់តុកៅអីគ្រូនិងសិស្ស សម្ភាររៀននិងបង្រៀន ជាដើម។

ក្នុងន័យនេះ ក្រសួងបានពិនិត្យឃើញថា ដើម្បីធានាការបន្តប្រតិបត្តិការការផ្តល់សេវាអប់រំប្រកបដោយភាពទាន់ពេលវេលានិងមាននិរន្តរភាពក្នុងការចូលរួមស្តារឡើងវិញនូវស្ថានភាពសាលារៀនសាធារណៈដែលរងផលប៉ះពាល់ឱ្យមានភាពជាប្រក្រតីឡើងវិញ ក្រសួងសូមណែនាំជូនអង្គភាពថ្នាក់កណ្តាលនិងមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ដូចខាងក្រោម៖

១-គ្រប់អង្គភាព ត្រូវបង្វែរឥណទានថវិកាឆ្នាំ២០២៦ ពីសកម្មភាពផ្សេងៗ ដែលមិនសូវចាំបាច់និងបន្ទាន់ ទៅជួយគាំទ្រសាលារៀនសាធារណៈ ដែលរងគ្រោះដោយសង្គ្រាមឈ្លានពានតាមតំបន់ព្រំដែនប្រទេសកម្ពុជានិងថៃ ដោយត្រូវវិភាជន៍ក្នុងទំហំឥណទានថវិកាចំនួន១៥% យ៉ាងតិចនៃឥណទានថវិកាស្ថិតក្នុងជំពូក គណនី អនុគណនី៖



អាសយដ្ឋាន៖ អគារលេខ ៨០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
info@moeys.gov.kh / administration@moeys.gov.kh
ទូរស័ព្ទ៖ (+៨៥៥) ២៣ ២២០ ៦៧៣ / ២២០ ៣០៤
www.moeys.gov.kh

-ជំពូក៦០(ការទិញ) អនុគណនី(៦០០២១ ៦០០៥២ ៦០០៥៣ និង៦០០៥៥)

-ជំពូក៦១(សេវាកម្ម) អនុគណនី( ៦១០៤១ ៦១១០៣ ៦១១២១ ៦១១២២ និង៦១១២៣)

-ជំពូក គណនី អនុគណនីផ្សេងៗ តាមការស្ម័គ្រចិត្តបន្ថែមរបស់អង្គភាព

២-ចំពោះកញ្ចប់ឥណទានថវិកា ដែលបានវិភាជន៍ត្រង់ចំណុចទី១ខាងលើ ត្រូវរក្សាទុកនិងប្រើប្រាស់ដោយអង្គភាពសាមីសម្រាប់ចុះជួយគាំទ្រដល់ការស្តារឡើងវិញ ឱ្យមានប្រក្រតីភាពជូនសាលារៀនគោលដៅទាន់ពេលវេលាក្នុងពេលដែលគ្រឹះស្ថានទាំងនោះ កំពុងប្រឈមកង្វះនូវការផ្តល់សេវាអប់រំ សម្ភារបរិក្ខារបច្ចេកទេស សម្ភារប្រើប្រាស់តុកៅអីសិស្សនិងគ្រូ សម្ភាររៀននិងបង្រៀន។ល។

៣-គ្រប់អង្គភាព ត្រូវធ្វើវិចារណកម្មចំណាយលើមុខសញ្ញាចំណាយរបស់អង្គភាពសាមី ឱ្យបានត្រឹមត្រូវ ច្បាស់លាស់និងគ្រប់ជ្រុងជ្រោយ ដើម្បីជាមូលដ្ឋានក្នុងការកៀរគរធនធានហិរញ្ញវត្ថុនិងសម្ភារៈសម្រាប់ចូលរួមគាំទ្រសាលារៀនសាធារណៈគោលដៅប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់

៤-គ្រប់អង្គភាព ត្រូវរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ២០២៦(AOP)ជាថ្មីឡើងវិញ ធ្វើយ៉ាងណាឱ្យស្របជាមួយសកម្មភាពដែលបានកែសម្រួល ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការពិនិត្យតាមដាននិងវាយតម្លៃប្រសិទ្ធភាពការងារ

៥-អគ្គនាយកដ្ឋានអប់រំ ត្រូវរៀបចំបញ្ជីឈ្មោះសាលារៀនសាធារណៈគោលដៅ ដែលរងផលប៉ះពាល់ពីសង្គ្រាមឈ្លានពានជូនអង្គភាព ឱ្យបានមុនថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៦ ដើម្បីជាមូលដ្ឋានសម្រាប់ការចងសម្ព័ន្ធមេត្រីភាពក្នុងការចុះជួយគាំទ្រ ឱ្យប្រកបដោយភាពច្បាស់លាស់និងទំនួលខុសត្រូវខ្ពស់

៦-នាយកដ្ឋានហិរញ្ញវត្ថុ ត្រូវរៀបចំទម្រង់ ស្តីពីការផ្ទេរឥណទានថវិកាឆ្នាំ២០២៦ ជូនអង្គភាព ឱ្យបានមុនថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៦ ដោយបង្វែរពីសកម្មភាពផ្សេងៗ ទៅជួយគាំទ្រសាលារៀនសាធារណៈគោលដៅ

៧-នាយកដ្ឋានពិនិត្យតាមដាននិងវាយតម្លៃ ត្រូវរៀបចំទម្រង់របាយការណ៍សមិទ្ធកម្មជូនអង្គភាព ឱ្យបានមុនថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៦ ព្រមទាំងបូកសរុបរបាយការណ៍សមិទ្ធកម្ម ស្តីពីការចុះជួយគាំទ្រសាលារៀនសាធារណៈគោលដៅជូនថ្នាក់ដឹកនាំក្រសួងឱ្យទាន់ពេលវេលា

៨-នាយកដ្ឋាននីតិកម្ម ត្រូវរៀបចំទម្រង់ ស្តីពីការចុះកិច្ចព្រមព្រៀងចងសម្ព័ន្ធមេត្រីភាព រវាងអង្គភាពជាមួយសាលារៀនសាធារណៈគោលដៅជូនអង្គភាព ឱ្យបានមុនថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៦ ដើម្បីចូលរួមពន្លឿនការអភិវឌ្ឍជូនគ្រឹះស្ថានសិក្សាឱ្យមានភាពប្រសើរឡើងវិញ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាប្រធានអង្គភាពមេត្តាជ្រាបនិងចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ តាមការគួរ។

សូម ឯកឧត្តម លោកជំទាវ លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**

- អគ្គលេខាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី
  " ដើម្បីជូនជ្រាបជាព័ត៌មាន "
- កាលប្បវត្តិ
- ឯកសារ នា.ហិរញ្ញវត្ថុ